នស/រកត/០៦០៩/៧០៥

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការបង្កើតអាជ្ញាធរទន្លេសាប

**យើង**

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

ROYAUME DU CAMBODGE

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងវបនីយជីវមណ្ឌលបឹងទន្លេសាប
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១._**

ត្រូវបានបង្កើតអាជ្ញាធរមួយ សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប មានឈ្មោះថា **អាជ្ញាធរទន្លេសាប** ដែលហៅជាអក្សរកាត់ថា **អ.ទ.ស.** ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល ។

**មាត្រា ២._**

វិសាលភាពនៃតំបន់ទន្លេសាប ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ២
## សមាសភាព

**មាត្រា ៣.-**

អ.ទ.ស. មានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| - ឧបនាយករដ្ឋមន្ត្រី ឬ ទេសរដ្ឋមន្ត្រី ឬ រដ្ឋមន្ត្រី | | ប្រធាន |
| - ឥស្សរជនជាន់ខ្ពស់មួយចំនួន | | អនុប្រធាន |
| - រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងបរិស្ថាន | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងផែនការ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងសុខាភិបាល | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ០១រូប | សមាជិក |
| - រដ្ឋមន្ត្រី ឬរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១រូប | សមាជិក |
| - អនុប្រធាន ឬអគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ០១រូប | សមាជិក |
| - ប្រធាន ឬអនុប្រធានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | ០១រូប | សមាជិក |
| - ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | | សមាជិក |
| - អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | | សមាជិក |
| - អគ្គលេខាធិការអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | | សមាជិក |
| - អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា | | សមាជិក |

ROYAUME DU CAMBODGE ROYAL

- អគ្គនាយករដ្ឋាករអប្សរា សមាជិក
- អភិបាលខេត្តកំពង់ឆ្នាំង សមាជិក
- អភិបាលខេត្តពោធិ៍សាត់ សមាជិក
- អភិបាលខេត្តបាត់ដំបង សមាជិក
- អភិបាលខេត្តបន្ទាយមានជ័យ សមាជិក
- អភិបាលខេត្តសៀមរាប សមាជិក
- អភិបាលខេត្តកំពង់ធំ សមាជិក
- អភិបាលខេត្តកំពង់ចាម សមាជិក
- អភិបាលខេត្តកណ្ដាល សមាជិក ។

សមាសភាពជាក់ស្ដែងរបស់ **អ.ទ.ស.** ត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៣
## ការរៀបចំ និង ការប្រព្រឹត្តទៅរបស់ អ.ទ.ស.

**មាត្រា ៤.-**

**អ.ទ.ស.** មានតួនាទី ភារកិច្ច សម្រាប់សម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាប ដូចតទៅ៖

- ជាសេនាធិការផ្ដល់ឱ្យរាជរដ្ឋាភិបាលលើរាល់គម្រោង ដោយធ្វើការសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងផ្ដល់អនុសាសន៍ជូនរាជរដ្ឋាភិបាល

- សហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ និងដៃគូអភិវឌ្ឍនានា ដើម្បីរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ កម្មវិធី និងគម្រោងផ្សេងៗ

- សម្របសម្រួលរាល់សកម្មភាព ដែលកំពុងអនុវត្ត គ្រោងនឹងអនុវត្ត របស់ក្រសួងស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា ដែលមាននៅក្នុងតំបន់ទន្លេសាប ដើម្បីឱ្យការងារមានភាពរលូនជាមួយគ្នាប្រកបដោយប្រសិទ្ធភាព

- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងនានា ដើម្បីជំរុញឱ្យប្រតិបត្តិករពាក់ព័ន្ធអនុវត្តស្របតាមយុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាល

- ធ្វើជាតំណាងរាជរដ្ឋាភិបាលក្នុងសកម្មភាពការងាររួមមាន កិច្ចប្រជុំ ការចរចា និងការដោះស្រាយរាល់បញ្ហាដែលអាចកើតមានជាយថាហេតុ

- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ កិច្ចសន្យាទាំងឡាយ ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល

- ជាសមភាគីជាមួយគ្រប់ដៃគូអភិវឌ្ឍទាំងអស់ក្នុងការរួមគ្នាពិចារណា ដើម្បីកំណត់សកម្មភាពដែលត្រូវអនុវត្ត
- ប្រមូល វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មាន ទិន្នន័យ ដើម្បីផ្សព្វផ្សាយ និងចែករំលែកដល់អ្នកពាក់ព័ន្ធ
- អប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដល់អ្នកពាក់ព័ន្ធ
- រាយការណ៍ជូនរាជរដ្ឋាភិបាលអំពីសកម្មភាពការងារសំខាន់ៗ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា ៥.-**

**អ.ទ.ស.** មានគណៈកម្មាធិការប្រតិបត្តិមួយ សម្រាប់ដឹកនាំការងារប្រចាំថ្ងៃ ដោយមានការណែនាំ និងចង្អុលទិសពីរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានសមាសភាព ដូចតទៅ៖

| | |
|---|---|
| - ប្រធាន អ.ទ.ស. | ប្រធាន |
| - អនុប្រធាន អ.ទ.ស. | អនុប្រធាន |
| - អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក |
| - អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាន អ.ទ.ស. | សមាជិក។ |

**មាត្រា ៦.-**

**អ.ទ.ស.** ដឹកនាំដោយប្រធានមួយរូប មានឋានៈទាបបំផុតស្មើរដ្ឋមន្ត្រីជាអ្នកទទួលខុសត្រូវរួមចំពោះមុខរាជរដ្ឋាភិបាល អមដោយអនុប្រធាន និងទីប្រឹក្សាមួយចំនួនជាជំនួយការ។

**មាត្រា ៧.-**

**អ.ទ.ស.** មានអគ្គលេខាធិការដ្ឋានមួយ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ និងចាត់ការទូទៅលើការងារសម្របសម្រួល ទំនាក់ទំនង និងសហការរវាង ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលនានា សម្រាប់គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ទន្លេសាបប្រកបដោយនិរន្តរភាព។

អគ្គលេខាធិការដ្ឋាន **អ.ទ.ស.** ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈស្មើរដ្ឋលេខាធិការអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ។

អគ្គលេខាធិការដ្ឋានត្រូវអនុវត្តការងារទៅតាមការណែនាំរបស់ប្រធាន។

**មាត្រា ៨.-**

ដើម្បីបំពេញការងាររបស់ខ្លួន ជូនរាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាពខ្ពស់ **អ.ទ.ស.** ត្រូវមានតំណាងឈរជើងតាមដាន និងផ្តល់យោបល់នៅក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងអង្គប្រជុំអន្តរក្រសួងផ្សេងៗ ពាក់ព័ន្ធនឹងកិច្ចការទន្លេសាបដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី ឬដោយក្រសួង ស្ថាប័ននានា។

**អ.ខ.ស.** មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់នៃក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធនានា ឬឥស្សរជនដែលមានបទពិសោធ និងសមត្ថភាពខ្ពស់ ដើម្បីចូលរួមផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួន ។

ក្នុងរយៈពេល ៣ (បី) ខែ **អ.ខ.ស.** ត្រូវកោះប្រជុំសាមញ្ញម្តង ។ ក្នុងករណីចាំបាច់ ប្រធាន **អ.ខ.ស.** ឬ គណៈកម្មាធិការប្រតិបត្តិនៃ **អ.ខ.ស.** អាចកោះប្រជុំវិសាមញ្ញ ។ ករណីប្រធានអវត្តមាន អនុប្រធានមានសិទ្ធិពេញលេញក្នុងការដឹកនាំកិច្ចប្រជុំតាមការណែនាំរបស់ប្រធាន ។

ក្នុងរយៈពេល ១ (មួយ) ខែ គណៈកម្មាធិការប្រតិបត្តិនៃ **អ.ខ.ស.** ត្រូវប្រជុំសាមញ្ញម្តង ។

**មាត្រា ៩.-**

ការតែងតាំងមន្ត្រីរាជការ ការរៀបចំប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន **អ.ខ.ស.** ជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ១០.-**

**អ.ខ.ស.** មានសិទ្ធិប្រើត្រាដោយឡែក និងមានទីស្នាក់ការកំណត់ដោយទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ១១.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ខ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤
## ប្រភពធនធានថវិកា

**មាត្រា ១២.-**

ប្រភពធនធានថវិការបស់ **អ.ខ.ស.** សម្រាប់បំពេញការងាររបស់ខ្លួន បានមកពី ៖

- ថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែកនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- អំណោយ និងវិភាគទានពីដៃគូអភិវឌ្ឍ សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា
- ជំនួយឥតសំណង ឬកម្ចីដែលធ្វើឡើងតាមការយល់ព្រមពីរាជរដ្ឋាភិបាល ។

**អ.ខ.ស.** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ជំនួយផ្នែកបច្ចេកទេស និងសម្ភារៈផ្សេងៗទៀត ពីប្រភពក្នុង ឬក្រៅប្រទេស សម្រាប់បម្រើសេចក្តីត្រូវការ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ឱ្យមានប្រសិទ្ធភាព ។



## ជំពូកទី ៥

## អវសានបញ្ញត្តិ

**មាត្រា ១៣.-**

ព្រះរាជក្រឹត្យនេះជំនួសព្រះរាជក្រឹត្យលេខ នស/រកត/០៩០៧/៤១២ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការបង្កើតអាជ្ញាធរអាងទន្លេសាប ដែលត្រូវបាននិរាករណ៍ ។

**មាត្រា ១៤.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកត.០៦០៩.៧១៤ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ ៧៤០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**